ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Sep-2012, 09:41
CMS/CFO: Ly Bunloung

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ៖ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២

**ជូនចំពោះ:** លោកស្រី Susan Lamb, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**ពី:** Wendy Lobwein, មន្ត្រីសម្របសម្រួលនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**កម្មវត្ថុ:** បច្ចុប្បន្នភាពស្តីពីសាក្សីអ្នកជំនាញឈ្មោះ **Philip Short (TCE-65)**

នាងខ្ញុំសរសេរលិខិតនេះដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានស្នើសុំព័ត៌មានបន្ថែមអំពីការរៀបចំដែលត្រូវបានធ្វើឡើងសម្រាប់ការស្តាប់សក្ខីកម្ម នាពេលខាងមុខរបស់អ្នកជំនាញឈ្មោះ Philip Short (TCE-65) និងវត្តមានរបស់គាត់នៅថ្ងៃខាងមុខ។

ការត្រៀមរៀបចំសម្រាប់សក្ខីកម្មរបស់លោក Short ក្នុងអំឡុងខែ តុលា ឆ្នាំ ២០១២ (ឬក្នុងអំឡុងខែណាមួយក្នុងឆ្នាំ ២០១២ ដែលតុលាការបានស្នើសុំ) គឺជាការរៀបចំដែលលំបាកស្មុគស្មាញណាស់ ដោយហេតុថា លោក Short ជាប់រវល់ច្រើនក្នុងគម្រោងជាក់លាក់មួយពេញមួយឆ្នាំ ២០១២ នេះ ដែលធ្វើឲ្យគាត់ពិបាកខ្លាំងក្នុងការរកពេលទំនេរ សម្រាប់ពេលវេលាដែលតុលាការបានស្នើសុំក្នុងអំឡុងឆ្នាំនេះ។ ពីដំបូង លោក Short បានស្នើសុំឲ្យកំណត់កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មរបស់គាត់ក្នុងឆ្នាំ ២០១៣ ប្រសិនបើអាចធ្វើទៅបាន។

កាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានទាក់ទងទៅលោក Short តាមរយៈសារអេឡិចត្រូនិកដើម្បីជូនដំណឹងទៅគាត់ថា ជនជាប់ចោទ អៀង សារី មានជំងឺ និងពុំអាចចូលរួមសវនាការបានឡើយនាពេលបច្ចុប្បន្ន ហើយអង្គជំនុំជម្រះសាលាដំបូងកំពុងពិនិត្យស្វែងរកជម្រើសនានាទាក់ទិននឹងការស្តាប់សក្ខីកម្មរបស់គាត់ ប្រសិនបើមានការសន្និដ្ឋានផ្នែកវេជ្ជសាស្ត្រថា អៀង សារី នៅតែពុំមានលទ្ធភាពដើម្បីចូលរួមសវនាការក្នុងរយៈពេលដ៏យូរខាងមុខ។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានជូនដំណឹងទៅលោក Philip Short ទៀតថា អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការដោយផ្ទាល់មាត់មួយជាមួយភាគីនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ដើម្បីពិភាក្សាអំពីបញ្ហានេះ ហើយអង្គភាពគាំពារសាក្សី និងអ្នកជំនាញកំពុងស្នើសុំឱ្យគាត់ជូនដំណឹងអំពីផលប៉ះពាល់ទៅលើរូបគាត់ និងវត្តមានរបស់គាត់នៅថ្ងៃខាងមុខដែលបណ្តាលមកពីការកែប្រែណាមួយ។

លោក Short បានបញ្ជាក់ជាថ្មីថា គាត់ពេញចិត្តនឹងផ្តល់សក្ខីកម្មរបស់គាត់ក្នុងអំឡុងឆ្នាំ ២០១៣ ហើយគាត់បានស្នើសុំឱ្យនាងខ្ញុំបញ្ជាក់អំពីចំណុចនេះជូនអង្គជំនុំជម្រះសាលាដំបូង។ គាត់នឹងមានវត្តមាននៅដើមឆ្នាំ ២០១៣ ពោលគឺចាប់ពីពាក់កណ្តាលខែ មករា ដល់ពាក់កណ្តាលខែ កុម្ភៈ ឆ្នាំ ២០១៣ ហើយក៏គាត់អាចពិភាក្សាអំពីកាលបរិច្ឆេទផ្សេងៗទៀតបានផងដែរ។ គាត់យល់ថា ការកំណត់យកកាលបរិច្ឆេទនៅចុងឆ្នាំ ២០១២ វិញនេះពិតជាពិបាកណាស់។ តាមការពិត ប្រសិនបើនៅក្នុងសប្តាហ៍នេះ ពុំមានការកំណត់កាលបរិច្ឆេទណាមួយដែលអាចទទួលយកបានទាំងអស់គ្នាទេ គាត់នឹងពុំមានលទ្ធភាពចូលរួមបានឡើយ។

ផលវិបាកផ្នែកហិរញ្ញវត្ថុនៃការកែប្រែលើការរៀបចំផ្នែកភស្តុភារនាពេលបច្ចុប្បន្ន គឺតុលាការនឹងត្រូវចេញសោហ៊ុយជាទឹកប្រាក់ចំនួនចន្លោះពី ២០០ ដុល្លារសហរដ្ឋអាមេរិក ទៅ ៧០០ ដុល្លារសហរដ្ឋអាមេរិក ដែលតួលេខស្ថាពរអាស្រ័យទៅលើកត្តាផ្សេងៗ។

នាងខ្ញុំអាចឆ្លើយសំណួរ ឬផ្តល់ព័ត៌មានបន្ថែមតាមដែលលោកស្រីត្រូវការ។

Original EN: 00848134-00848134